**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៤៩..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បី ត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាព

www.pheakdeylaw.com

ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ទី ចំរុន្ទផល** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម | **លេខ ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម | **លូ រ៉ាមីន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម | **អ៊ុំ សាមី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម | **ប៉ាច ហាមផាន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម | **ខ៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម | **ផៃ ម៉ុនឈឿន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តម | **ថោ សេដ្ឋារ៉ាណា** | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩-ឯកឧត្តម | **ហៅ ភាន់** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

ក្រៅពីសមាសភាពខាងលើនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរ៉ែនិងថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់បញ្ជូនតំណាង០១រូប ដែលមាន មុខតំណែងចាប់ពីអគ្គនាយកឡើង ឲ្យចូលរួមជាសមាជិកក្រុមជំនួយការនេះ។

**ប្រការ២ .-**

ក្រៅពីសមាសភាពដូចមានចែងក្នុងប្រការ១ខាងលើ ប្រធានក្រុមជំនួយការត្រូវសុំយោបល់ណែនាំពី**ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំក្រុមជំនួយការតាមការចាំបាច់។

**ប្រការ៣ .-**

ប្រធាន អនុប្រធាន សមាជិក ក្រុមជំនួយការអាចស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នសាមី ដើម្បីប្រើប្រាស់មន្ត្រីក្នុងក្រសួង ស្ថាប័ន របស់ខ្លួនឲ្យជួយការងារនៅក្នុងក្រុមជំនួយការ តាមការចាំបាច់។

**ប្រការ៤ .-**

ក្រុមជំនួយការមានភារកិច្ចធ្វើជាសេនាធិការជូន **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** លើការងារសំខាន់ៗ ដូចខាងក្រោម៖

- ទទួលរបាយការណ៍ពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុប អំពីសកម្មភាពការងាររបស់ក្រុមការងារឲ្យបានទៀងទាត់ តាមការកំណត់របស់រាជរដ្ឋាភិបាល។
- ធ្វើការបូកសរុបវាយតម្លៃអំពីសមិទ្ធផល បញ្ហាប្រឈម ក្នុងសកម្មភាពការងារចុះជួយមូលដ្ឋាន។



www.pheakdeylaw.com

- សហការជាមួយក្រុមការងារ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធសិក្សាអំពីក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់និងវិធានការនានាក្នុងការដោះស្រាយបញ្ហាប្រឈម ដែលក្រុមការងារមិនអាចដោះស្រាយបាន ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល។
- សហការជាមួយក្រុមការងារនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកសំណើពាក់ព័ន្ធការស្នើសុំកែសម្រួល ផ្លាស់ប្តូរ បំពេញបន្ថែមសមាសភាពក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន។
- ស្នើសុំមន្ត្រីពីក្រសួង ស្ថាប័ន ដូចមានចែងក្នុងប្រការ១ ដើម្បីជួយបំពេញការងារប្រចាំថ្ងៃរបស់ក្រុមជំនួយការ។
- បំពេញការងារកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពី **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

**ប្រការ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០. ខែ ៣ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-ប្រធានក្រុមការងារថ្នាក់ជាតិចុះ រាជធានី ខេត្ត*
*-សាលារាជធានី ខេត្ត*
*-សាមីខ្លួនដូចមានចែងក្នុងប្រការ១*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com